**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងបរិស្ថាន**
លេខៈ ០១៤ សសរ ប.ស្ក

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តន៍គម្រោង ធ្វើបញ្ជីសារពើភ័ណ្ឌ BLACK CARBON នៅក្នុងបរិយាកាស

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- យោងលិខិតលេខ២៣៥ សភភព ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៨ របស់សាកលវិទ្យាល័យភូមិន្ទភ្នំពេញ
- យោងលិខិតលេខ៤៥៦ ធទឧ ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងធនធានទឹក និងឧតុនិយម
- យោងលិខិតលេខ៦៤៩ វបក ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ របស់វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា
- យោងលិខិតលេខ០៨៩ សណ.អកអច ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៨ របស់អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
- យោងលិខិតលេខ៩១៨ សក.អផគ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងសាធារណការ និងដឹកជញ្ជូន
- យោងលិខិតលេខ២៨០៩ កសក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- យោងលិខិតលេខ៧៨១ ឧស.បវប ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងឧស្សាហកម្ម និង សិប្បកម្ម
- យោងលិខិតលេខ០៤២៧ រថ.ថកថ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងរ៉ែ និងថាមពល

## សម្រេច

**ប្រការ១**.-

ត្រូវបានបង្កើតក្រុមការងារបច្ចេកទេសសម្រាប់អនុវត្តន៍គម្រោង ធ្វើបញ្ជីសារពើភ័ណ្ឌ Black Carbon នៅក្នុង បរិយាកាស ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១- ឯកឧត្តម **ហេង ណារ៉េត** | អគ្គនាយកគាំពារបរិស្ថាន | ប្រធាន |
| ២- លោក **ប៉ាក សុខាវ៉ាវុត** | អគ្គនាយករង នៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន | អនុប្រធាន |
| ៣- លោក **ធីវ សុភារិទ្ធ** | ប្រធាននាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសំឡេង | សមាជិក |
| ៤- លោក **ភិន ណារ៉ុង** | ប្រធាននាយកដ្ឋានរដ្ឋបាល ផែនការ និងហិរញ្ញវត្ថុ | សមាជិក |
| ៥- លោក **ប្រុក ណូរីដា** | ប្រធាននាយកដ្ឋាននៃក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |
| ៦- លោក **ជា ណារ៉ា** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសំឡេង | សមាជិក |
| ៧- លោក **ប៉ាក វណ្ណលី** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសំឡេង | សមាជិក |
| ៨- លោក **បាក់ ប៊ុណ្ណា** | អនុប្រធាននាយកដ្ឋាន នៃក្រសួងធនធនទឹក និងឧតុនិយម | សមាជិក |
| ៩- លោកស្រី **ឃ្លោក វិចិត្ររដ្ឋា** | អនុប្រធាននាយកដ្ឋាន នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព | សមាជិកា |
| ១០- លោក **ឈុន ឌីលុច** | អនុប្រធាននាយកដ្ឋាន នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១- លោក **ចុង ប៊ូ** | អនុប្រធាននាយកដ្ឋាន នៃក្រសួងឧស្សាហកម្ម និងសិប្បកម្ម | សមាជិក |
| ១២- លោក **សូ វាសនា** | អនុប្រធាននាយកដ្ឋាន នៃក្រសួងរ៉ែ និងថាមពល | សមាជិក |
| ១៣- លោក **កុក សុធា** | សាស្ត្រាចារ្យ នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ១៤- កញ្ញាបណ្ឌិត **ហាក់ ដាណែត** | គ្រូបង្រៀនកម្រិតឧត្តម នៃវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | សមាជិកា |
| ១៥- **ប្រធានមន្ទីរបរិស្ថានរាជធានី-ខេត្ត** | | សមាជិក |

**ប្រការ២**.-

ក្រុមការងារនេះមានភារកិច្ច ដូចតទៅ៖

- ចូលរួមអនុវត្តសកម្មភាព ដែលជាតម្រូវការចាំបាច់នានាសម្រាប់ធ្វើឲ្យការអនុវត្តគម្រោងមានភាពរលូន
- បំពេញការងារជាសេនាធិការជូនថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធ ក្នុងការសិក្សាផ្តល់យោបល់សម្រាប់ធ្វើ ជាមូលដ្ឋានសម្រេចចិត្ត និងជំរុញការចូលរួមអនុវត្តគម្រោងឲ្យមានប្រសិទ្ធភាពខ្ពស់
- លើកស្នើសុំគោលនយោបាយជាតិ ឬផែនការជាតិលើការអនុវត្តគម្រោង លើការធ្វើបញ្ជីសារពើភ័ណ្ឌ Black Carbon នៅក្នុងបរិយាកាស ជូនថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធពិនិត្យសម្រេច
- ចូលរួមផ្តល់យោបល់លើរាល់សេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត និងផែនការសកម្មភាពទាក់ទង ទៅនឹងការអនុវត្តគម្រោង
- ផ្លាស់ប្តូរយោបល់ សិក្សានិងវាយតម្លៃពីបញ្ហាប្រឈម និងចំណុចខ្វះខាត លើការអនុវត្តគម្រោង និង រាយការណ៍ជូនថ្នាក់ដឹកនាំស្ថាប័នពាក់ព័ន្ធជ្រាបពីតម្រូវការចាំបាច់បន្ថែម

- ធ្វើការវាយតម្លៃលើចំណេះដឹង និងកម្រិតនៃការទទួលស្គាល់ចំពោះភាគីពាក់ព័ន្ធលើសារធាតុបំពុលបរិយាកាសរយៈពេលខ្លី (Short-Lived Climate Pollutants)
- កំណត់ពីវិស័យដែលមានសក្តានុពល និងរាល់សកម្មភាពដើម្បីកាត់បន្ថយសារធាតុបំពុលបរិយាកាសរយៈពេលខ្លី
- ការចូលរួមក្នុងការបណ្តុះបណ្តាល ស្តីពីប្រព័ន្ធផែនការជម្រើសថាមពលរយៈពេលវែង-ការគណនាអត្ថប្រយោជន៍រួម (LEAP-IBC) និងបង្កើតបញ្ជីសារពើភ័ណ្ឌកាបូនខ្មៅថ្នាក់ជាតិ ដែលគ្រប់ដណ្តប់លើវិស័យគន្លឹះ
- បញ្ជ្រាបគំនិតផ្តួចផ្តើមរបស់សម្ព័ន្ធខ្យល់ស្អាត (Climate and Clean Air Coalition) រួមបញ្ចូលទាំងផែនការយុទ្ធសាស្ត្រកាត់បន្ថយលើសារធាតុបំពុលបរិយាកាសរយៈពេលខ្លី (SLCPs) ចូលទៅក្នុងផែនការយុទ្ធសាស្ត្រថ្នាក់ជាតិ និងផែនការសកម្មភាពរបស់ស្ថាប័នរាជរដ្ឋាភិបាល ឬក្រសួង។

**ប្រការ៣**.-

ឯកឧត្តម លោក លោកស្រី សមាជិកក្រុមការងារបច្ចេកទេសអន្តរក្រសួងទាំងអស់ ត្រូវអនុវត្តតាមភារកិច្ចដូចមានចែងក្នុងប្រការ២ ខាងលើ និងត្រូវចូលរួមប្រជុំឲ្យបានទៀងទាត់តាមការអញ្ជើញរបស់ប្រធានក្រុមការងារបច្ចេកទេស។

**ប្រការ៤**.-

ក្រុមការងារបច្ចេកទេសនេះ មានលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានគ្រប់គ្រងគុណភាពខ្យល់ និងសំឡេង អគ្គនាយកដ្ឋានគាំពារបរិស្ថាន នៃក្រសួងបរិស្ថាន។ លេខាធិការអចិន្ត្រៃយ៍មានភារកិច្ចរៀបចំការប្រជុំក្រុមការងារបច្ចេកទេស ធ្វើរបាយការណ៍កិច្ចប្រជុំ និងផ្តល់ព័ត៌មាននានាទាក់ទងនឹងការអនុវត្តគម្រោងធ្វើបញ្ជីសារពើភ័ណ្ឌ Black Carbon នៅក្នុងបរិយាកាស។

**ប្រការ៥**.-

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៦**.-

អនុរដ្ឋលេខាធិការ នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព អគ្គនាយកនៃអគ្គនាយកដ្ឋានគាំពារបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានចំណេះដឹង និងព័ត៌មានបរិស្ថាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលការពារនិងអភិរក្សធម្មជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង ឯកឧត្តម លោកជំទាវ លោក លោកស្រី និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ខែ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ឆ្នាំ២០១៨

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ ៦ «ដើម្បីអនុវត្ត»
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ